ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក សិ ក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អគ្គលេខាធិការដ្ឋាន

ក្រុមលទ្ធកម្ម

លេខ:...១/២៦...កសក.អល.កល

# សេចក្តីជូនដំណឹង

## ស្តីពីការអញ្ជើញចូលរួមពិគ្រោះថ្លៃស្តីពីការបោះពុម្ព ប្រចាំឆ្នាំ២០២៦ របស់អង្គភាពថវិកា អគ្គលេខាធិការដ្ឋាន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

អង្គភាពថវិកា អគ្គលេខាធិការដ្ឋាន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាស ឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា អគ្គលេខាធិការដ្ឋាន នឹងដាក់ឱ្យពិគ្រោះថ្លៃជាសាធារណៈដើម្បីជ្រើសរើសទទួលអ្នកផ្គត់ផ្គង់ការបោះពុម្ព ប្រចាំឆ្នាំ២០២៦ របស់អង្គភាពថវិកា អគ្គលេខាធិការដ្ឋាន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

អង្គភាពថវិកា អគ្គលេខាធិការដ្ឋាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំឯកសារសម្រាប់ ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមពិគ្រោះថ្លៃ និងមានដាក់លក់នៅក្រុមលទ្ធកម្ម នៃអង្គភាពថវិកា អគ្គលេខាធិការដ្ឋាន ដែលមានអាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី..១៤.. ខែ..កុម្ភៈ.....ឆ្នាំ២០២៦ តទៅរៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទាក់ទងលេខ០៦០ ២១ ២១ ៨៣)។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនក្រុមលទ្ធកម្ម នៃអង្គភាពថវិកា អគ្គលេខាធិការដ្ឋាន យ៉ាងយូរបំផុតត្រឹមថ្ងៃទី..២៧......ខែ..កុម្ភៈ...ឆ្នាំ២០២៦ វេលាម៉ោង..១០:០០...........។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមអាសយដ្ឋាន ខាងលើ វេលាម៉ោង..១០:០០.... ថ្ងៃទី...២៧.....ខែ..កុម្ភៈ..ឆ្នាំ២០២៦។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយក្រុមលទ្ធកម្ម នៃអង្គភាពថវិកា អគ្គលេខាធិការដ្ឋាន ដើម្បីទិញឯកសារពិគ្រោះថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការពិគ្រោះថ្លៃនេះ។

ថ្ងៃ..ព្រហស្បតិ៍ ១០រោច...ខែ..មាឃ...ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី...១២.......ខែ...កុម្ភៈ... ឆ្នាំ២០២៦

**ប្រធានក្រុមលទ្ធកម្ម**

**អង្គភាពថវិកា អគ្គលេខាធិការដ្ឋាន**

បណ្ឌិត សរ ចិត្រា

**ចម្លងជូន៖**

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ

-ឯកសារ កាលប្បវត្តិ